**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Apr-2011, 09:19
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការបន្ថាញពីបញ្ហាផ្នែកច្បាប់របស់លោក អៀង សារី ដែលគាត់មានបំណងលើកឡើងក្នុងសវនាការបឋម

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គជំនុំជម្រះសាលាដំបូង** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្ដម | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ធូ មណី | លោក Andrew CAYLEY |
| | ចៅក្រម យ៉ា សុខន | |
| | ចៅក្រម Silvia CARTWRIGHT | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Jean-Marc LAVERGNE | |
| | ចៅក្រមបំរុង យូរ ឧត្ដារ៉ា | |
| | ចៅក្រមបំរុង Claudia FENZ | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមដាក់ការបង្ហាញអំពីបញ្ហាផ្នែកច្បាប់ដែលគាត់មានបំណងលើកឡើងក្នុងសវនាការបឋម អនុលោមតាមដីការបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីដាក់ឯកសារដើម្បីរៀបចំសវនាការ ("ដីកាបង្គាប់")[1]។ មេធាវីការពារក្តីបានលើកឡើងពីបញ្ហាផ្នែកច្បាប់ជាច្រើនរួចមកហើយជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង។ បញ្ហាទាំងនេះមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ ឬក៏អាចត្រូវបានសម្រេចតាមរយៈសេចក្តីសម្រេចផ្ទាល់មាត់ ប៉ុន្តែមិនបានចេញសំអាងហេតុជាលាយល័ក្ខអក្សរណាមួយ ដែលមេធាវីការពារក្តីអាចប្តឹងឧទ្ធរណ៍បានឡើយ។ មេធាវីការពារក្តីសូមរក្សាសិទ្ធិកែប្រែបញ្ជីនេះ ប្រសិនបើបញ្ហាមួយចំនួនត្រូវបានដោះស្រាយមុនសវនាការបឋម ឬបើមានលេចឡើងនូវបញ្ហាថ្មីៗណាមួយក្នុងចន្លោះពេលពីការដាក់បញ្ជីនេះ និងសវនាការបឋម។

## I. **អំណះអំណាង**

១. មេធាវីការពារក្តី មានបំណងលើកឡើងនូវអញ្ញត្រកម្មបឋមនីមួយៗរបស់ខ្លួនទាក់ទងនឹងយុត្តាធិការរបស់ អវតក លើលោក អៀង សារី។ ជាពិសេស មេធាវីការពារក្តី នឹងលើកនូវអំណះអំណាងដូចខាងក្រោមនេះ៖

ក) អវតក មិនមានយុត្តាធិការលើលោក អៀង សារី ឡើយដោយសារតែព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោសដែលបានផ្តល់ឲ្យគាត់ដោយស្របច្បាប់ និងនៅជាធរមាននៅឡើយ។

ខ) អវតក មិនមានយុត្តាធិការលើលោក អៀង សារី ឡើយដោយសារតែ *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* (*ne bis in idem*)។

គ) អវតក មិនមានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិប្រឆាំងលោក អៀង សារី ឡើយ។

ឃ) អវតក មិនមានយុត្តាធិការដើម្បីអនុវត្តការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវប្រឆាំងលោក អៀង សារី ឡើយ។

ង) ប្រសិនបើ អវតក មានយុត្តាធិការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អវតក ក៏នៅតែមានយុត្តាធិការ ដែលមានដែនកំណត់ក្នុងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងលោក អៀង សារី។

---

[1] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជសដ ដីកាបង្គាប់អោយភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ មករា ២០១១ ឯកសារលេខ E9, ERN: 00635754-00635759។

ច) អវតក មិនមានយុត្តាធិការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើប្រឆាំងលោក អៀង សារី ឡើយ។

ឆ) អវតក មិនមានយុត្តាធិការអនុវត្តឧក្រិដ្ឋកម្មថ្នាក់ជាតិប្រឆាំងលោក អៀង សារី ឡើយ។

២. មេធាវីការពារក្តី មានបំណងលើកឡើងពីបញ្ហាខាងក្រោមនេះដែលទាក់ទងនឹងកំហុសក្នុងការស៊ើបសួរ និងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖

ក)ថាតើអង្គជំនុំជម្រះសាលាដំបូង ត្រូវតែបើកសវនាការស្តីពីការប្រព្រឹត្តទៅនៃការស៊ើបសួរ ដើម្បីវាយតម្លៃថាតើការស៊ើបសួរនេះមានយុត្តិធម៌ឬអត់ និងដើម្បីវាយតម្លៃពីទំងន់ដែលត្រូវផ្តល់លើភស្តុតាងដែលប្រមូលបានក្នុងអំឡុងពេលស៊ើបសួរ។

ខ)ដោយសារតែកំហុសឆ្គង ថាតើអង្គជំនុំជម្រះសាលាដំបូងត្រូវតែលុបផ្នែកណាមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែរឬអត់។

៣. មេធាវីការពារក្តីមានបំណងលើកបញ្ហាខាងក្រោមទាក់ទងទៅនឹងការធ្វើសក្ខីកម្មរបស់សាក្សី៖

ក) ថាតើ ឌុច ត្រូវតែធ្វើសក្ខីកម្មដោយមានសម្បថដែរ ឬអត់ ។

ខ) ថាតើសក្ខីកម្មរបស់ ឌុច អាចយកមកប្រើដែរ ឬអត់ ប្រសិនបើ ឌុច មិនចូលខ្លួនជាសាក្សី ឬ ប្រសិនបើគាត់ចូលខ្លួនជាសក្សី ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យចោទសួរដោយបដិភាគីនោះ ។

គ) ថាតើសហព្រះរាជអាជ្ញា និង អង្គជំនុំជម្រះសាលាដំបូង ត្រូវតែផ្តល់បញ្ជីនៃឧទាហរណ៍នានានៅពេលដែលពួកគេជឿជាក់ថា ឌុច ជាមនុស្សមិនស្មោះត្រង់ដែរ ឬអត់ ។

ឃ) ថាតើដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែធ្វើសក្ខីកម្មដោយមានសម្បថដែរ ឬអត់ ប្រសិនបើពួកគេត្រូវធ្វើសក្ខីកម្មអំពីអង្គហេតុ ជាជាងដោយគ្រាន់តែការធ្វើសក្ខីកម្មអំពីការទាមទារសំណងរបស់ពួកគេនោះ ។

៤. មេធាវីការពារក្តីមានបំណងលើកបញ្ហាដូចខាងក្រោមទាក់ទងទៅនឹងដំណើរការសវនាការ:

ក) ថាតើការជំនុំជម្រះក្តីនឹងត្រូវដំណើរការដោយអនុវត្តយ៉ាងតឹងរ៉ឹងតាមប្រព័ន្ធសួរដេញដោលដោយចៅក្រម (inquisitorial system) ដែរ ឬអត់ក្នុងករណី ដែលតាមរយៈនេះ៖

- ចៅក្រមអង្គជំនុំជម្រះសាលាដំបូងអានសំណុំរឿងទាំងមូលនៅមុនពេលសវនាការ ។

- ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនឹងជ្រើសរើសរចនាសម្ព័ន្ធ និងប្រធានបទនៃសំណុំរឿង ។
- ចៅក្រមអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសសាក្សី និងឯកសារ ដែលចៅក្រមនឹងលើកមកសំអាង ហើយភាគីគ្រាន់តែដាក់បន្ថែមបញ្ជីទាំងនេះ និង
- ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនឹងដាក់សំណួរទៅកាន់សាក្សីមុនគេ ជាបន្ទាប់ភាគីដាក់សួរសំណួរបន្ថែមនៅចុងក្រោយ ។

ខ) ប្រសិនការជំនុំជម្រះក្តីនេះ មិនត្រូវបានដំណើរការដោយអនុវត្តយ៉ាងតឹងរ៉ឹងតាមប្រព័ន្ធសួរដេញដោលដោយចៅក្រមនេះទេ ថាតើសិទ្ធិរបស់លោក អៀង សារី ត្រូវការពារយ៉ាងដូម្តេច ។

៥. មេធាវីការពារក្តី មានបំណងលើកបញ្ហាខាងក្រោមទាក់ទងទៅនឹងអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង៖

ក) ថាតើអង្គជំនុំជម្រះអាចបង្គាប់អង្គភាពបកប្រែ (ITU) ឱ្យបញ្ឈប់ការបកប្រែឯកសាររបស់មេធាវីការពារក្តីដែរ ឬអត់ ហើយប្រសិនបើអង្គជំនុំជម្រះបង្គាប់អង្គភាពអ្នកបកប្រែ ឱ្យបញ្ឈប់ការបកប្រែឯកសាររបស់មេធាវីការពារក្តីមែន ថាតើអង្គជំនុំជម្រះនេះមានអំណាចអ្វីដើម្បីធ្វើដូច្នេះ ។

ខ) ថាតើអង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេចលើបញ្ហាច្បាប់ និងបញ្ហានីតិវិធី តាមរយៈអនុស្សរណៈក្រៅផ្លូវការ ឬ តាមសារអេឡិចត្រូនិកដែរ ឬអត់ ជាជាងសេចក្តីសម្រេច និងដីកាសម្រេចផ្លូវការនោះ ។

គ) ថាតើអង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសម្រេច ឬដីកាបង្គាប់ដែលគ្មានហត្ថលេខារបស់អង្គជំនុំជម្រះទាំងមូលដែរ ឬអត់ ។

៦. មេធាវីការពារក្តីមានបំណងលើកបញ្ហាថា តើសិទ្ធិរបស់លោក អៀង សារី ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នឹងត្រូវបានរំលោភដែរ ឬអត់ បើសិនជាពេលវេលាកំណត់ដើម្បីដាក់សារណាឆ្លើយតប នឹងចម្លើយតបទៅនឹងសារណា និងសំណើនានា ចាប់ផ្តើមគិតភ្លាមៗបន្ទាប់ពីគាត់ទទួលបានឯកសារជាពីរភាសា បើទោះបីភាសាទាំងពីរនេះមិនមែនជាភាសាធ្វើការរបស់ក្រុមការពារក្តីនោះក៏ដោយ ។

៧. មេធាវីការពារក្តីមានបំណងលើកបញ្ហានៃសម្បទារបស់លោក អៀង សារី ដើម្បីចូលរួមក្នុង

សវនាការ ។

៨. មេធាវីការពារក្ដីមានបំណងលើកបញ្ហាដទៃផ្សេងទៀត ដែលអាចកើតឡើងពីការសន្និដ្ឋាននានា ដែលធ្វើឡើងដោយភាគីដទៃទៀត ពីកិច្ចប្រជុំរៀបចំសវនាការនាពេលក្រោយ ឬនៅឯសវនាការបឋម ។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកការចង្អុលបង្ហាញនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១១**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**